**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការក្រសួងយុត្តិធម៌**

**លេខ : ៦២កយប្រក/០៨**

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០០៨

# ប្រកាស

## ស្តីពី

## ការប្រើប្រាស់របាំងក្នុងបន្ទប់សវនាការ និង បន្ទប់សវនាការភ្ជាប់បណ្តាញទូរទស្សន៍ ដើម្បីយកសក្ខីកម្មពីកុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា បានសុំចូលជាភាគី នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញសេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧កបធ.ច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញអនុក្រឹត្យលេខ ១៩អនក្រ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញសារាចរណែនាំលេខ ០៣ កយ.សណន/២០០៥ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ២០០៥ របស់ក្រសួងយុត្តិធម៌ស្តីពីការអនុវត្តន៍គោលការណ៍នៃ ច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលចូលជាធរមាន ពាក់ព័ន្ធទៅនឹងជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ
- យោងលិខិតលេខ៦១៧កយរប/០៧ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ ស្តីពីការប្រើរបាំងនៅពេលសវនាការសំរាប់ជនរងគ្រោះ/សាក្សី ជាកុមារ
- យោងតាមការចាំបាច់

## សម្រេច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.៊**

របាំងក្នុងបន្ទប់សវនាការ និង បន្ទប់សវនាការដែលភ្ជាប់បណ្តាញទូរទស្សន៍សំរាប់យកសាក្ខីកម្មពីកុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះមានគោលបំណងដើម្បីផ្តល់បរិយាកាសមួយដែលមានសុវត្ថិភាពនិងមានការគាំទ្រ ឱ្យកុមារឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះអាចផ្តល់នូវពត៌មានដែលខ្លួនបានពើបប្រទះ ដើម្បីទាញយកយកនូវពត៌មានត្រឹមត្រូវតាមរបៀបមួយដែលមិននាំមុខ ប៉ុន្តែសមស្របទៅតាមកំរិតលូតលាស់របស់កុមារ ដើម្បីទទួលបាននូវពត៌ស្តីពីបទល្មើស ឱ្យបានច្រើនតាមតែអាចធ្វើទៅបាន ដើម្បីបង្កលក្ខណៈងាយស្រួលដំណើរការជំនុំជំរះនៅតាមតុលាការ ដើម្បីកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តខ្លាំងទៅលើកុមារឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះដោយធ្វើការបន្ថយជាអប្បបរមានូវចំនួននៃការសម្ភាសន៍និងចំនួនអ្នកសម្ភាសន៍ និង ដើម្បីបន្ថយនូវការគំរាមកំហែងចំពោះសុវត្ថិភាពរបស់កុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះតាមរយៈការបន្ថយការបង្ហាញខ្លួនឱ្យជនល្មើសឃើញ។

**ប្រការ ២.៊**

**១-** ជាគោលការណ៍ របាំងក្នុងបន្ទប់សវនាការត្រូវប្រើជាវិធានការការពារជាចម្បងនៅគ្រប់រឿងក្តី ដែលមានការពាក់ព័ន្ធនឹងកុមារ ឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ។

២- ក្នុងករណីកុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ ត្រូវការនូវការការពារពិសេសដែលរបាំងក្នុងបន្ទប់សវនាការមិនអាចការពារបាន អាចធ្វើការយកសាក្តីកម្មតាមរយៈការភ្ជាប់បណ្តាញទូរទស្សន៍។ (ចំពោះបន្ទប់សវនាការដែលបំពាក់បណ្តាញទុរទស្សន៍រួចហើយ)

៣- គួរប្រើរបាំងក្នុងបន្ទប់សវនាការ និង បន្ទប់សវនាការដែលភ្ជាប់បណ្តាញទូរទស្សន៍សំរាប់យកសាក្តីកម្មពីកុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ :

ក- នៅក្នុងរឿងក្តីព្រហ្មទណ្ឌនៅពេលយកសក្ខីកម្មពីកុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ

ខ- នៅពេលជនជាប់ចោទមានវត្តមាននៅក្នុងបន្ទប់សវនាការ

គ- ក្នុងករណីដែលការយកសក្ខីកម្មដោយមានវត្តមានជនជាប់ចោទនៅក្នុងបន្ទប់សវនាការអាចបណ្តាលឱ្យមានការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរដល់កុមារឬជនរងគ្រោះឬសាក្សី ដែលងាយរងគ្រោះ

លើកលែងតែកុមារ ឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះមិនចង់ឱ្យប្រើរបាំងក្នុងបន្ទប់សវនាការ និងបណ្តាញទូរទស្សន៍ ហើយចៅក្រមយល់ឃើញថាជាឧត្តមប្រយោជន៍របស់កុមារឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់ជាមួយកុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ មេធាវីរបស់អ្នកទាំងនោះ និង/ឬ បុគ្គលិកសង្គមកិច្ច។

## ជំពូក ២

## របាំងក្នុងបន្ទប់សវនាការ

### ប្រការ ៣.-

មុនពេលសវនាការ ចៅក្រមត្រូវពន្យល់ដល់កុមារឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ និង/ឬមេធាវី ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការ ពីគោលបំណងនៃការប្រើរបាំង ។

### ប្រការ ៤.-

១- របាំងត្រូវដាក់រួចជាស្រេច មុននឹងកុមារឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះចូលមកកាន់បន្ទប់សវនាការ។

២- របាំងត្រូវដាក់ក្នុងទីតាំងដែលធ្វើឱ្យកុមារឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ ចៅក្រមព្រះរាជអាជ្ញា ឬ មេធាវីអាចមើលឃើញ និងស្តាប់ឮគ្នាទៅវិញទៅមក។

៣- ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ ជាពិសេសមេធាវីការពារ គួរអាចសង្កេតមើលឃើញអាកប្បកិរិយា និង ស្តាប់ឮចម្លើយរបស់កុមារឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះបានច្បាស់។

**ប្រការ ៥.៚**

១- កុមារឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ ត្រូវរង់ចាំនៅក្នុងកន្លែងដាច់ដោយឡែកពីគ្នា ហើយអ្នកទាំងនោះចូលក្នុងបន្ទប់សវនាការតែក្នុងខណៈដែលដល់វេនត្រូវផ្តល់សក្ខីកម្ម ។

២- កុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ គួរអមដំណើរដោយនីតិជនសមស្របដូចជាឪពុកឬម្តាយ បុគ្គលិកសង្គមកិច្ច ក្រឡាបញ្ជី មន្ត្រីនគរបាល ឬ ជនសមស្របផ្សេងទៀត នៅពេលចូល និង ចាកចេញពីបន្ទប់សវនាការ ។

៣- កុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ គួរចូលនិងចាកចេញពីបន្ទប់សវនាការនៅក្នុងលក្ខណៈជៀសវាងការទាក់ទង ឬ ការមើលឃើញជនជាប់ចោទ ជាអាទិ៍ :

ក- កុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ អង្គុយនៅចំហៀងម្ខាងនៃរបាំងមុនពេលជនជាប់ចោទចូលបន្ទប់សវនាការ ហើយជនជាប់ចោទចាកចេញមុន កុមារឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះចាកចេញ

ខ- ឱ្យជនជាប់ចោទអង្គុយនៅចំហៀងម្ខាងទៀតនៃរបាំងមុនពេលកុមារឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះចូលបន្ទប់សវនាការ

គ- ជនជាប់ចោទត្រូវស្ថិតនៅឯចំហៀងម្ខាងទៀតនៃរបាំង នៅរាល់ពេលដែលកុមារឬជនរងគ្រោះដែលងាយរងគ្រោះនៅក្នុងបន្ទប់សវនាការ

ឃ- ប្រសិនបើតម្រូវឱ្យកុមារ ឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះចង្អុលបង្ហាញជនល្មើស គួរយករបាំងចេញ ហើយដាក់របាំងមកវិញក្រោយពីបានបញ្ចប់នីតិវិធីចង្អុល។

**ប្រការ ៦.៚**

១- ការផ្តល់សក្ខីកម្មដោយកុមារ ឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ ត្រូវប្រព្រឹត្តទៅជាសម្ងាត់។

២- ដើម្បីការពារ និង បង្កើតបរិយាកាសស្ងប់ស្ងៀមល្អសំរាប់កុមារ ឬ ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ តុលាការអាចបង្គាប់ឱ្យមានការផ្លាស់ប្តូរទីកន្លែង និង ចល័តជនគ្រប់រូបដែលត្រូវបានអនុញ្ញាតឱ្យមានវត្តមាននៅក្នុងបន្ទប់សវនាការ ក្នុងនោះរួមមានភាគីនៃរឿងក្តី ព្រះរាជអាជ្ញា មេធាវី បុគ្គលិកតុលាការ សាក្សី និងអ្នកគាំទ្រដរាបណាកុមារ ឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី អាចមើលឃើញ និងស្តាប់ឮគ្នាទៅវិញទៅមកទាំងអស់គ្នា ហើយមេធាវីការពារអាចសង្កេតមើលឃើញអាកប្បកិរិយារបស់កុមារ ឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ។

**ប្រការ ៧.-**

១- អ្នកគាំទ្រដែលត្រូវបានតុលាការយល់ព្រម ដូចជាឪពុកម្តាយ អ្នកអាណាព្យាបាល បុគ្គលិកសង្គមកិច្ច ឬ នីតិជនដែលកុមារជ្រើសរើស ត្រូវបានអនុញ្ញាតឱ្យអង្គុយ ក្បែរកុមារនៅចំហៀងម្ខាងនៃរបាំង ប្រសិនបើចាំបាច់ ។

២- ចៅក្រមគួរធ្វើការណែនាំដល់អ្នកគាំទ្រមិនឱ្យបញ្ឆេះកុមារ ។

**ប្រការ ៨.-**

១- កុមារ ឬជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះគួរត្រូវបានអនុញ្ញាតឱ្យចេញពីបន្ទប់សវនាការភ្លាម បន្ទាប់ពីអ្នកទាំងនោះបានបញ្ចប់ការផ្តល់សក្ខីកម្ម ។

២- របាំងត្រូវយកចេញតែក្នុងខណៈដែលកុមារ ឬ សាក្សីឬជនរងគ្រោះដែលងាយរងគ្រោះបានចាកចេញពីបន្ទប់សវនាការ ។

## ជំពូក ៣

## ការដាក់ពាក្យសុំឱ្យយកសក្ខីកម្មពីកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះតាមរយៈបន្ទប់សវនាការភ្ជាប់បណ្តាញទូរទស្សន៍

**ប្រការ ៩.-**

ព្រះរាជអាជ្ញា ឬ មេធាវីអាចដាក់ពាក្យសុំឱ្យមានការបង្គាប់ឱ្យយកសក្ខីកម្មពីកុមារ ឬ ជនរងគ្រោះឬសាក្សីងាយរងគ្រោះដែលនៅក្នុងបន្ទប់មួយក្រៅបន្ទប់សវនាការតាមរយៈបណ្តាញទូរទស្សន៍មើលឃើញរូបភាពផ្ទាល់ នៅពេលចាប់ផ្តើមសវនាការ។

**ប្រការ ១០.-**

១- នៅពេលពិចារណាពីពាក្យសុំដូចមានចែងក្នុងប្រការ៩នៃប្រកាសនេះ ចៅក្រមត្រូវសួរកុមារ ឬ ជនរងគ្រោះឬសាក្សីងាយរងគ្រោះ ដោយមិនមានវត្តមានជនជាប់ចោទ ដើម្បីឱ្យដឹងពីអារម្មណ៍របស់កុមារ ឬ ជនរងគ្រោះឬសាក្សីងាយរងគ្រោះ ទាក់ទងនឹងការយកសក្ខីកម្មនៅក្នុងបន្ទប់សវនាការ ។

២- ចៅក្រមត្រូវស្វះស្វែងកំណត់នូវកំរិតនៃការភ័យខ្លាចឬភាពមិនស្រួលចិត្តរបស់កុមារឬជនរងគ្រោះ ឬសាក្សីងាយរងគ្រោះ នៅពេលជនជាប់ចោទមានវត្តមាននៅក្នុងបន្ទប់សវនាការ កំរិតសុវត្ថិភាពរបស់កុមារ ឬ ជនរងគ្រោះឬសាក្សីងាយរងគ្រោះនៅពេលនីតិជនផ្សេងទៀតមានវត្តមាននៅក្នុងបន្ទប់សវនាការ អារម្មណ៍នៅពេលឃើញជនជាប់ចោទ និង ការព្រួយបារម្ភផ្សេងទៀតទាក់ទងនឹងសុវត្ថិភាពនៅពេលអនាគត ប្រសិនបើធ្វើការយកសក្ខីកម្មនៅមុខជនជាប់ចោទ។

**ប្រការ ១១.-**

ចៅក្រមត្រូវចេញដីកាបង្គាប់ឱ្យប្រើ ឬបដិសេធមិនឱ្យប្រើការយកសាក្ខីកម្មតាមរយៈការភ្ជាប់បណ្តាញទូរទស្សន៏ ដោយមានសំអាងហេតុ ដោយពិចារណា ទៅលើកត្តា :

ក- អាយុ និងកំរិតលូតលាស់របស់កុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ និងសុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវអារម្មណ៍ រួមទាំងពិការភាពផ្លូវកាយនិងផ្លូវចិត្ត។

ខ- ប្រភេទបទល្មើស ទំនាក់ទំនងរវាងកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះជាមួយជនជាប់ចោទ ការគំរាមកំហែងដែលធ្លាប់មាន ឬសក្តានុពលនៃការគំរាមកំហែងរបស់ជនជាប់ចោទ ឬ ជនដទៃទៀត ដែលអាចនឹងមានមកលើកុមារឬជនរងគ្រោះ ឬសាក្សីងាយរងគ្រោះ

គ- ការទទួលរងនូវរបួសផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវអារម្មណ៍ដែលកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះបានជួបប្រទះនាពេលកន្លងមក

ឃ- ប្រតិកម្មរបស់កុមារ ឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ ចំពោះការប៉ះទង្គិចមុនៗ នៅក្នុងតុលាការ ឬ នៅកន្លែងផ្សេងទៀត

ង- ប្រតិកម្មមុនការជំនុំជំរះ ដែលកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះបានបង្ហាញឱ្យដឹងនៅពេលពិភាក្សាអំពីប្រធានបទនៃការធ្វើសក្ខីកម្មជាមួយអ្នកទាំងនោះ

ច- សញ្ញាជាក់លាក់ណាមួយនៃការថប់អារម្មណ៍ដែលកុមារឬជនរងគ្រោះ ឬសាក្សីងាយរងគ្រោះបានបង្ហាញឱ្យដឹង និងឥរិយាបទរបស់សមាជិកគ្រួសាររបស់អ្នកទាំងនោះចំពោះព្រឹត្តិការណ៍ដែលខ្លួននឹងផ្តល់សក្ខីកម្ម និង

ឆ- កត្តាពាក់ព័ន្ធផ្សេងៗទៀត ដូចជាបរិយាកាសតុលាការ និង បែបផែននានានៃនីតិវិធីតុលាការ។

## ជំពូក ៤
## តួនាទី និង ភារកិច្ចរបស់អ្នកគាំទ្រ និង បុគ្គលិកតុលាការ

**ប្រការ ១២.-**

**១**- ក្នុងករណីតុលាការបង្គាប់ឱ្យសួរយកសក្ខីកម្មកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះតាមរយៈការភ្ជាប់បណ្តាញទូរទស្សន៍ អ្នកគាំទ្រត្រូវមានវត្តមាននៅក្នុងអំឡុងពេលយកសក្ខីកម្មពីកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះទាំងស្រុង។

២- ចំពោះរឿងក្តីទាក់ទងនឹងបទល្មើសផ្លូវភេទលើកុមារី អ្នកគាំទ្រគួរតែជាស្ត្រី ក្នុងករណីអាចធ្វើទៅបាន។

៣- ជនដែលអាចត្រូវបានចាត់តាំងឱ្យធ្វើជាអ្នកគាំទ្ររួមមានបុគ្គលិកសង្គមកិច្ច ឪពុកឬម្តាយឬសាច់ញាតិជិតដិតរបស់កុមារ អ្នកអាណាព្យាបាលរបស់កុមារ មន្ត្រីនគរបាល ឬជនផ្សេងទៀតដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវអំពីការងារសង្គមកិច្ច ឬ ការការពារកុមារ។

**ប្រការ ១៣.-**

បុគ្គលិកតុលាការដែលអមកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ គួរមានវត្តមាននៅក្នុងអំឡុងពេលយកសក្ខីកម្មពីកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះទាំងស្រុង។ តួនាទីចម្បងរបស់បុគ្គលិកអមគឺដើម្បីធានាថាឧបករណ៍ភ្ជាប់បណ្តាញផ្ទាល់ ដំណើរការបានល្អត្រឹមត្រូវ។ ប្រសិនបើទទួលការបណ្តុះបណ្តាលត្រឹមត្រូវ បុគ្គលិកអមក៏អាចធ្វើជាអ្នកផ្តល់ការគាំទ្រដែរ។

**ប្រការ ១៤.-**

មុននឹងកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះផ្តល់/បង្ហាញភស្តុតាង :

ក-បុគ្គលិកតុលាការត្រូវធានាថាបន្ទប់សាក្សីត្រូវបានរៀបចំរួចរាល់សំរាប់កុមារ ឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ

ខ-បុគ្គលិកតុលាការត្រូវអមដំណើរកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ និង អ្នកគាំទ្ររបស់អ្នកទាំងនោះ ទៅកាន់បន្ទប់រង់ចាំ

គ-អ្នកគាំទ្រត្រូវនៅជាមួយកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះគ្រប់ពេល

ឃ-បុគ្គលិកតុលាការត្រូវអមដំណើរកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ និង អ្នកគាំទ្ររបស់អ្នកទាំងនោះទៅកាន់បន្ទប់ភ្ជាប់បណ្តាញទូរទស្សន៍។

**ប្រការ ១៥.-**

នៅក្នុងបន្ទប់ភ្ជាប់បណ្តាញទូរទស្សន៍ បុគ្គលិកតុលាការនិង/ឬអ្នកគាំទ្រនឹង :

ក- អង្គុយនៅនឹងកន្លែងជាមួយកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ និង ភ្ជាប់ឧគ្ឃោសនសព្ទទៅនឹងសំលៀកបំពាក់របស់ខ្លួន

ខ- បិទ/ព្យួរផ្លាកបំរាមនៅតាមច្រកដើរ រួចបិទទ្វារ

គ- អង្គុយនៅចំហៀងម្ខាងអមកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ ដែលនៅចំពីមុខម៉ាស៊ីនចាប់យករូបភាព

ឃ- តាមការដឹកនាំរបស់ចៅក្រម អានពាក្យសម្បថឱ្យកុមារឬជនរងគ្រោះ ឬ សាក្សីងាយរងគ្រោះថាតាម ទៅតាមស្ថានភាពសមស្រប

ង- ធ្វើទំនាក់ទំនងអំពីការពាក់ព័ន្ធនានាជាមួយចៅក្រម

ច- មានវត្តមានជាមួយកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ ក្នុងអំឡុងពេល អ្នកទាំងនោះនៅក្នុងបន្ទប់

ឆ- ធានាថាកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះអាចមើលឃើញ និង ស្តាប់ឮច្បាស់នូវការបញ្ជូន(រូបភាពនិងសម្លេង)

ជ- ធានាថាគេអាចមើលឃើញ និងស្តាប់ឮច្បាស់នូវរូបភាពនិងសម្លេងរបស់ កុមារ ឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ តាមរយៈទូរទស្សន៍ភ្ជាប់បណ្តាញផ្ទាល់ នៅគ្រប់ពេលទាំងអស់

ឈ- ស្ថិតនៅកន្លែងដែលមេធាវី និង ជនជាប់ចោទអាចមើលឃើញនៅក្នុងអំឡុងពេលផ្តល់/បង្ហាញភស្តុតាង

ញ- ក្នុងករណីត្រូវប្រគល់/បង្ហាញវត្ថុតាងទៅកុមារ ឬជនរងគ្រោះ ឬសាក្សីងាយរងគ្រោះ ទៅតាមបញ្ជារបស់តុលាការ ត្រូវប្រគល់វត្ថុតាងទៅឱ្យអ្នកទាំងនោះ ដោយមិនបាច់មានយោបល់

ដ- បង្ការមិនឱ្យជនដែលគ្មានការអនុញ្ញាតចូលក្នុងបន្ទប់

ឋ- ធានាថាមិនមានការប៉ុនប៉ងដើម្បីរំខាន ធ្វើការជ្រៀតជ្រែក ឬបំភិតបំភ័យកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះ ពីសំណាក់ជនណាមួយដែលមានវត្តមាននៅក្នុងបន្ទប់ភ្ជាប់បណ្តាញទូរទស្សន៍បន្តផ្ទាល់។

**ប្រការ ១៦.-**

អ្នកគាំទ្រឬអ្នកបច្ចេកទេសដែលនៅក្នុងបន្ទប់ភ្ជាប់បណ្តាញទូរទស្សន៍មិនត្រូវ :

ក- និយាយជាមួយកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះអំពីរឿងក្តី ឬ ភស្តុតាងរបស់អ្នកទាំងនោះ នៅមុនឬក្នុងអំឡុងពេលដំណើរការនីតិវិធី ឬ ដើម្បីរំខានដល់ដំណើរការនីតិវិធី

ខ- រំខាន ឬ ជ្រៀតជ្រែក/អន្តរាគមន៍ នៅពេលកំពុងដំណើរការនីតិវិធី លើកលែងតែប្រាប់ចៅក្រមឱ្យដឹងពីបញ្ហាអ្វីមួយ

គ- ធ្វើឱ្យមានឬព្យាយាមធ្វើឱ្យមានឥទ្ធិពលលើកុមារឬជនរងគ្រោះ ឬសាក្សីងាយរងគ្រោះ ទោះក្នុងរូបភាពណាក៏ដោយ។

## ជំពូក ៥

## ការការពារកុមារ ឬ ជនរងគ្រោះឬសាក្សីងាយរងគ្រោះ

**ប្រការ ១៧.-**

**១**- ការផ្តល់សក្ខីកម្មតាមរយៈបណ្តាញទូរទស្សន៍ត្រូវធ្វើជាសម្ងាត់។

**២**- ប្រសិនបើចាំបាច់ឱ្យកុមារឬជនរងគ្រោះឬសាក្សីងាយរងគ្រោះត្រូវចង្អុលបង្ហាញជនជាប់ចោទនៅពេលជំនុំជម្រះ តុលាការអាចអនុញ្ញាតឱ្យកុមារ ឬ ជនរងគ្រោះឬសាក្សីងាយរងគ្រោះចូលមកកាន់បន្ទប់សវនាការ ក្នុងគោលបំណងមានកំរិតត្រឹមតែការចង្អុលបង្ហាញជនជាប់ចោទ ឬ តុលាការអាចអនុញ្ញាតឱ្យកុមារ ឬជនរងគ្រោះឬសាក្សីងាយរងគ្រោះចង្អុលបង្ហាញជនជាប់ចោទ ដោយធ្វើការសង្កេតរូបភាពជនជាប់ចោទនៅលើកញ្ចក់ទូរទស្សន៍ណាមួយ។

## ជំពូក ៦

## កំណត់ត្រា

**ប្រការ ១៨.-**

ការផ្តល់សក្ខីកម្មដោយកុមារ ឬ ជនរងគ្រោះឬសាក្សីងាយរងគ្រោះអាចត្រូវបានថតរក្សាទុកនៅក្នុងកាសែតវីដេអូ ឬ ថាសឌីជីថិលដែលត្រូវថតទុកជាកំណត់ត្រារបស់តុលាការ។ កាសែតវីដេអូ ឬ ថាសឌីជីថិលនោះត្រូវចាត់ទុកជាការសម្ងាត់ និងត្រូវធ្វើកំណត់សំគាល់ថាជាការសម្ងាត់។

## ជំពូក ៧

## អវសានប្បញ្ញត្តិ

**ប្រការ ១៩.-**

ប្រកាសនេះមានអានុភាពចាប់កាលបរិច្ឆេទចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា និង ត្រា**

**អង្គ វង្សវឌ្ឍានា**

**<u>ចំលងជូន</u>** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ក្រសួងមហាផ្ទៃ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  "ដើម្បីជូនជ្រាប"
- តុលាការ និង អយ្យការអមតុលាការគ្រប់ថ្នាក់
  "ដើម្បីអនុវត្ត"
- ឯកសារ និង កាលប្បវត្តិ